ផលិតចងក្រងដោយ NSW HEALTH DEPARTMENT

Khmer
June 2001
[DOH-7125]

# ជម្ងឺជីអាឌីអាហ្ស៊ីស (Giardiasis)

## Giardiasis

### តើជម្ងឺ Giardiasis ជាអ្វី?

- Giardiasis គឺជាជំងឺមួយប្រភេទដែលកើតឡើងជាចំបង នៅពោះវៀនតូចបណ្តាលមកពីប៉ារ៉ាស៊ីតឈ្មោះថា Giardia lamblia ។ ជម្ងឺ giardiasis ត្រូវបានគេរាយការណ៍ថាមានកើតនៅលើមនុស្ស និងសត្វផ្សេងៗ ។
- ជម្ងឺ giardiasis អាចយាយីមនុស្សគ្រប់រូប។ ទោះជាយ៉ាងណាក៏ដោយ ក៏ជម្ងឺនេះច្រើនយាយីទារក, កុមារ, និងជនពេញវ័យដែលមានអាយុពី ២០-៤០ ឆ្នាំ ។
- ជម្ងឺ giardiasis គឺជាប្រភេទជម្ងឺដែលត្រូវផ្តល់ដំណឹងទៅអាជ្ញាធរក្នុងរដ្ឋ NSW ដឹង។ មន្ទីរពិសោធន៍ដែលបញ្ជាក់ពីរោគវិនិច្ឆ័យត្រូវតែប្រាប់មន្ទីរសុខភាពសាធារណៈ ដែលត្រូវចាត់សកម្មភាព ដើម្បីបង្ការការឆ្លងការរាលដាលថែមទៀត ។ រាល់ការផ្តល់ដំណឹងទាំងអស់ត្រូវបានគេរក្សាភាពសម្ងាត់ ។

### តើជម្ងឺនេះឆ្លងរាលដាលយ៉ាងដូចម្តេច?

- មេរោគ Giardia មានវត្តមាននៅក្នុងលាមករបស់មនុស្ស ឬ សត្វដែលមានផ្ទុកមេរោគ ។ ការឆ្លងរោគកើតឡើងនៅពេលដែលមនុស្សណាម្នាក់ប៉ះពាល់ជាមួយលាមកដែលមានមេរោគ និង ហូបដោយប៉ារ៉ាស៊ីតនេះ។
- ការចំលងកើតឡើងញឹកញាប់បំផុតបើសិនមិនបានលាងដៃក្រោយពេលចេញពីបង្គន់ ឬ ក្រោយពីផ្លាស់ប្តូរកន្ទប, ដោយការទទួលទានទឹកដែលមានមេរោគនោះ, ដោយការប៉ះពាល់សត្វដែលមានមេរោគ និងក្នុងករណីកំរ តាមរយៈការបរិភោគអាហារដែលមានមេរោគ ។
- ការចំលងកើតឡើងញឹកញាប់បំផុតតាមរយៈការប៉ះពាល់រវាងមនុស្សនិងមនុស្ស នៅក្នុងស្ថានភាពផ្សេងៗគ្នា មានដូចជា នៅក្នុងផ្ទះ និងមជ្ឈមណ្ឌលថែរក្សាក្មេងជាដើម។
- ការចំលងអាចកើតឡើងតាមរយៈការរួមភេទដែលរួមទាំងការប៉ះពាល់ជាមួយលាមកផងដែរ។
- មនុស្សដែលងាយចំលងរោគបំផុត គឺនៅពេលដែលជននោះឈឺ ដោយចំលងមេរោគដែលមាននៅក្នុងលាមករបស់គេ (ដែលអាចកើតឡើងក្នុងរយៈពេលជាច្រើនខែ)។

### តើមានរោគសញ្ញាអ្វីខ្លះ ?

- រោគសញ្ញាដែលជួបប្រទះញឹកញាប់ជាងគេនៃជម្ងឺ gardiasis គឺ ការរាករូស, ចុកពោះ, ហើមឆ្អល់ពោះ, ចង្អោរ, លាមករាវរាងសប្រផេះនិងមានសំបោរ, អស់កំលាំង, និងស្រកទំងន់ ។
- មនុស្សខ្លះទៀតពុំមានចេញរោគសញ្ញាអ្វីទេ, តែទោះបីយ៉ាងណាក៏ដោយ ក៏ពួកគេនៅតែអាចចំលងជំងឺទៅអ្នកផ្សេងបាន ។

- បណ្ដាសញ្ញាដំបូងរបស់ជម្ងឺនេះនឹងស្ដែងឡើងក្នុងរវាង ៣-២៥ ថ្ងៃ (ជាមធ្យម ៧-១០ ថ្ងៃ) បន្ទាប់ពីជនណាម្នាក់បានឆ្លងមេរោគនេះ។
- មនុស្សភាគច្រើនដែលមានសុខភាពល្អនឹងជាសះស្បើយឡើងវិញក្នុងរវាង ៤-៦ អាទិត្យ ។ ជួនកាលរោគសញ្ញាទាំងឡាយអាចឋិតថេររយៈពេលយូរជាងធម្មតា ។

## តើគេធ្វើរោគវិនិច្ឆ័យ និង ព្យាបាលជម្ងឺនេះយ៉ាងដូចម្ដេច ?

- គេអាចធ្វើរោគវិនិច្ឆ័យជម្ងឺ giardiasis នេះតាមរយៈការពិនិត្យលាមកប៉ុណ្ណោះ ដោយការធ្វើតេស្តមួយ ដែលបញ្ជាដោយវេជ្ជបណ្ឌិត ។ សូមទៅជួបគ្រូពេទ្យបើសិនអ្នកមានរោគសញ្ញា ។
- ចំពោះជនណាដែលរាករូស ការទទួលទានទឹកឲ្យបានគ្រប់គ្រាន់ គឺជាការសំខាន់ ដើម្បីជៀសវាងការបាត់បង់ជាតិទឹក។
- ថ្នាំដែលមានវេជ្ជបញ្ជារួមមាន មេត្រូនីដាសុល (metronidazole ) និង ទីនីដាសុល (tinidazole) ដែលអាចព្យាបាលជម្ងឺ giardiasis បាន។

### មនុស្សដែលប្រឈមនឹងគ្រោះថ្នាក់បំផុត :

មនុស្សដែលប្រឈមនឹងគ្រោះថ្នាក់បំផុតក្នុងការឆ្លងជម្ងឺ giardiasis គឺ:

- មនុស្សដែលប៉ះពាល់ជាមួយក្មេងផ្ទុកមេរោគ មានដូចជា ក្មេងដទៃផ្សេងទៀត, ឪពុកម្ដាយ, បុគ្គលិកមណ្ឌលថែរក្សាក្មេង។
- មនុស្សដែលទទួលទានទឹកមានមេរោគដូចជាអ្នកឡើងភ្នំ, អ្នកបោះជំរំ។

## តើគេបង្ការជម្ងឺនេះយ៉ាងដូចម្ដេច ?

ដើម្បីជៀសវាងការកើតជម្ងឺ giardiasis គេត្រូវ ៖

- ជានិច្ចជាកាលលាងដៃជាមួយសាប៊ូនិងទឹកម៉ាស៊ីនឲ្យបានស្អាតបន្ទាប់ពីចេញពីបង្គន់, ប៉ះពាល់សត្វ, ផ្លាស់ប្ដូរ កន្ទប និង ការប៉ះពាល់ជាមួយលាមក, ធ្វើការងារក្នុងសួនច្បារ និង មុនពេលរៀបចំម្ហូបអាហារ និងភេសជ្ជៈ។
- មិនត្រូវទទួលទានទឹកស្ទឹង/ទន្លេ, បឹង, អូរ, ត្រពាំង និងអាង ដោយមិនបានដាំ ឬ មិនបានសំលាប់មេរោគឡើយ។ ការដាំទឹកដែលបានមកពីប្រភពទាំងនេះឲ្យពុះ ក្នុងរយៈពេលមួយនាទី នឹងសំលាប់ប៉ារ៉ាស៊ីត giardia ព្រមទាំងប៉ារ៉ាស៊ីតផ្សេងៗទៀត ។ ថ្នាំបន្សុទ្ធទឹកអាចសំលាប់មេរោគ giardia បាន ប៉ុន្តែអាចមិនសំលាប់មេរោគ crypto sporidium បានដែរ ។ ប្រដាប់ច្រោះទឹកខ្លះអាចច្រោះយកប៉ារ៉ាស៊ីតទាំងនេះចេញបាន ។
- ជៀសវាងការទទួលទានទឹកម៉ាស៊ីនដែលមិនបានដាំឆ្អិន និងអាហារឆៅនៅពេលធ្វើដំណើរទៅកាន់ប្រទេសទាំងឡាយ ដែលការផ្គត់ផ្គង់ទឹកអាចមិនមានសុវត្ថិភាព ។

ដើម្បីជៀសវាងការឆ្លងរាលដាលនៃជម្ងឺ giardiasis :

- កុំឲ្យក្មេងដែលរាករូសទៅសាលា, កន្លែងថែរក្សាក្មេង, ការលេងជាក្រុម ឬ អាងហែលទឹក រហូតដល់ពួកគេបាត់រាកទាំងស្រុង ។

បើសិនលោកអ្នកមានជម្ងឺ giardiasis ហើយនៅក្នុងស្ថានភាពអាចចំលងរោគទៅអ្នកផ្សេងនោះ ៖

- មិនត្រូវរៀបចំម្ហូបអាហារ ឬរៀបភេសជ្ជៈសំរាប់អ្នកផ្សេងទេ
- មិនត្រូវប្រើប្រាស់អាងហែលទឹកទេ
- មិនត្រូវប្រើកំរាលពូក ឬ ស្រោមខ្នើយ, កន្សែងពោះគោ និងសំភារៈបរិភោគអាហារជាមួយអ្នកឯទៃផ្សេងទៀតឡើយ ។

ព័ត៌មានបន្ថែម- **Public Health Units in NSW**

ចំពោះព័ត៌មានបន្ថែម សូមទាក់ទងវេជ្ជបណ្ឌិត មន្ទីរសុខភាពសាធារណៈតាមតំបន់ ឬមណ្ឌលសុខភាពក្នុងសហគមន៏របស់លោកអ្នក។ សូមមើល នៅត្រង់កន្លែង 'NSW Government' នៅផ្នែកខាងមុខនៃសៀវភៅ White Pages។

| | |
|---|---|
| **Metropolitan Areas** | |
| Central Sydney | 9515 3180 |
| South Eastern Sydney | 9382 8333 |
| Northern Sydney | 9477 9400 |
| South Western Sydney | 9828 5944 |
| Western Sydney | 9840 3603 |
| Wentworth | 4734 2022 |
| **Rural Areas** | |
| Central Coast | 4349 4845 |
| Mid North Coast | 6588 2750 |
| Mid Western | 6339 5548 |
| Hunter | 4924 6477 |
| Illawarra | 4255 2200 |
| New England | 6766 2288 |
| Northern Rivers | 6620 7500 |
| Macquarie | 6841 2216 |
| Southern | 4827 3428 |
| Greater Murray | 6021 4799 |
| Far West | (08) 8080 1499 |

**NSW Department of Health**
73 Miller Street
North Sydney NSW 2059
Tel. (02) 9391 9000
Fax. (02) 9391 9101
TTY. (02) 9391 9900

NSW Health website
www.health.nsw.gov.au